**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៥៤ អនក្រ**

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការ ក្រុមហ៊ុនអាកាសចរណ៍ជាតិ CAMBODIA ANGKOR AIR

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុនអាកាសចរណ៍ជាតិ CAMBODIA ANGKOR AIR ដែលមានសមាសភាពដូចរាយនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២. | ឯកឧត្តម **សូ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣. | ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៤. | ឯកឧត្តម **កែប ជុតិមា** | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ៥. | ឯកឧត្តម **ស៊ូ ភិរិន្ទ** | អភិបាល នៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ៦. | ឯកឧត្តម **ស្បោង សារ៉ាត់** | អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ៧. | ឯកឧត្តម **ម៉ោញ សំអាត** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានពិធីការ | សមាជិក |

www.pheakdeylaw.com

៨. ឯកឧត្តម **សយ សុខាន់** អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

៩. លោក **ម៉ម អំណត់** ជំនួយការខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១០. តំណាងគណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក

១១. តំណាងក្រុមហ៊ុនអាកាសចរណ៍ជាតិវៀតណាម សមាជិក

១២. តំណាងក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) សមាជិក

**ប្រការ ២ :** គណៈកម្មការរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុន CAMBODIA ANGKOR AIR មានភារកិច្ចដូចខាងក្រោម ÷

- រៀបចំសម្របសម្រួល និងធានាឱ្យកិច្ចដំណើរការ នៃការរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការក្រុមហ៊ុន CAMBODIA ANGKOR AIR អាចប្រព្រឹត្តទៅដោយរលូន និងទៅតាមកាលបរិច្ឆេទកំណត់
- សហការជាមួយកងកម្លាំងប្រដាប់អាវុធ សំដៅធានាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៃអង្គពិធីបរិវេណជុំវិញ និងគោលដៅសំខាន់ៗ
- ធ្វើគម្រោងថវិកាសម្រាប់ចំណាយលើការរៀបចំពិធី និងត្រៀមថវិកាបម្រុងសម្រាប់ចំណាយចំពោះមុខតាមការងារជាក់ស្តែង
- រៀបចំឯកសារចាំបាច់នានា និងធ្វើលិខិតយាង និងអញ្ជើញគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ។

**ប្រការ ៣ :** ដើម្បីអនុវត្តភារកិច្ចខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ គណៈកម្មការនេះអាចចាត់តាំងមន្ត្រីបន្ថែម ដើម្បីជួយការងារតាមការចាំបាច់។

**ប្រការ ៤ :** សមាជិកគណៈកម្មការខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានគណៈកម្មការ និងត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រធានគណៈកម្មការពីលទ្ធផលការងាររបស់ខ្លួន។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធានគណៈកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

ស ខេន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com